**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**
សំណុំរឿងព្រហ្មទណ្ឌលេខ ២៤
ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២១
សាលក្រមលេខ ៨២ (គ)
ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពត

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣។

បានបើកកិច្ចសួរដេញដោលជាសាធារណៈ នៅសាលាជំនុំជម្រះក្តីនៃសាលាដំបូងខេត្តកំពត នាថ្ងៃ ទី ១៩ ខែ មករា ឆ្នាំ២០២២ វេលាម៉ោង ៩:០០ នាទីព្រឹក។

**ចៅក្រមជំនុំជម្រះ**

**លោកស្រី [redacted] ចៅក្រមជំនុំជម្រះ**

**តំណាងអយ្យការ**

**លោក [redacted] ព្រះរាជអាជ្ញារង**

**ក្រឡាបញ្ជីសវនាការ**

**លោកស្រី [redacted] ក្រឡាបញ្ជីសវនាការ**

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៤ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] ភឿន ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត និងទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ មិនស្គាល់,ម្តាយឈ្មោះ [redacted] ជា (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ មាន (ធ្លាប់ជាប់ពន្ធនាគារ ០១ឆ្នាំកន្លះ ពីបទ លួច) ។

ជននេះជាប់ចោទពីបទ: ប៉ុងប៉ងលួច (កាបូប) ប្រព្រឹត្តនៅចំណុចអាគារសង្គ្រោះបន្ទាន់ មន្ទីរពេទ្យបង្អែកខេត្តកំពត ស្ថិតនៅភូមិកំពង់បាយ សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត កាលពីវេលាម៉ោង ១ រំលងអធ្រាត្រ ឆ្លងចូលថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

ដែលមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ។

-ជនរងគ្រោះឈ្មោះ [redacted] យេន ភេទស្រី អាយុ ៤៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិចំលងជ្រៃ ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីវេលាម៉ោង ០១ រំលងអធ្រាត្រ ឆ្លងចូលថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០២២ នៅចំណុចអាគារសង្គ្រោះបន្ទាន់ មន្ទីរពេទ្យបង្អែកខេត្តកំពត ស្ថិតនៅភូមិកំពង់បាយ សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត

មានករណី **ប៉ុងប៉ងលួច (កាបូប)**ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ[redacted] **ភឿន** ភេទប្រុស អាយុ ២៦ឆ្នាំ ខណៈជនរងគ្រោះឈ្មោះ[redacted] **យេន** កំពុងសម្រាកនៅមន្ទីរពេទ្យបង្អែកខេត្តកំពត ស្រាប់តែជនជាប់ចោទខាងលើបានធ្វើសកម្មភាពលួចកាបូបលុយរបស់ជនរងគ្រោះ តែត្រូវបានបុរសសម្រាកនៅក្បែរគ្នាតាមទាន់ ក៏បានឃាត់ខ្លួនជនជាប់ចោទប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ក្រោយការសាកសួរនៅចំពោះមុខតំណាងអយ្យការជនជាប់ចោទឈ្មោះ[redacted] **ភឿន** បានឆ្លើយសារភាពថាៈខ្លួនពិតជាបានធ្វើសកម្មភាពលួចកាបូបរបស់ជនរងគ្រោះខាងលើប្រាកដមែន ប៉ុន្តែពុំបានសម្រេចឡើយ។

-បានឃើញ កំណត់ហេតុស្តីពីការចូលខ្លួនភ្លាមលេខ ០៤ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពត ។

-បានឃើញកំណត់ហេតុជំនុំជម្រះចុះថ្ងៃទី ១៩ ខែ មករាឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពត។

-បានឃើញសំណុំរឿងជំនុំជម្រះលេខ ៥៤ ចុះថ្ងៃទី ០៤ ខែ មករាឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពត។

-បានឃើញសាលក្រមមុនអង្គសេចក្តីលេខ១៦ (គ) ចុះថ្ងៃទី ០៥ខែ មករាឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពត។

## នាពេលសវនាការ

-តាមចម្លើយជនជាប់ចោទឈ្មោះ[redacted] **ភឿន** បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ខ្ញុំគ្រាន់លូកដៃយកកាបូបគេយកមិនទាន់បានទេ ក៏ត្រូវម្ចាស់គេទាន់ ក៏ត្រូវម្ចាស់គេទាន់គេចាប់បាន។ លួចនៅមន្ទីរពេទ្យបង្អែកខេត្តកំពតនៅបន្ទប់សង្គ្រោះបន្ទាន់ លួចពេលយប់។ ខ្ញុំសព្វថ្ងៃអត់ធ្វើការអ្វីទេ នៅផ្ទះមើលម្តាយឈឺ ខ្ញុំទើបតែលួចគេតែ ០១ដងទេ ហើយមិនបានសម្រេចទៀត។ ពេលនេះខ្ញុំរាងចាលហើយ ខ្ញុំឈប់រៀនតាំងពីថ្នាក់ទី២ ព្រោះអត់លុយរៀនពេលឈប់រៀនខ្ញុំធ្វើសំណង់ ក្រោយមកក៏ឈប់វិញ។ នៅថ្ងៃនោះខ្ញុំគ្មានអាវុធទេ ហើយក៏គ្មានគំរោងទុកមុនទេ ដើរប៉ះឃើញលួចតែម្តង។ នៅថ្ងៃនោះជនរងគ្រោះកំពុងដេក ហើយមានបងប្អូនគេច្រើនដែរ ដែលដេកក្បែរជនរងគ្រោះ ខ្ញុំក៏បានលូកដៃទៅយកស្រាប់តែគេភ្ញាក់ទាន់ចាប់ខ្ញុំតែម្តងទៅ ។ថ្ងៃនោះខ្ញុំក៏ដេកពេទ្យដែរ ទៅផ្ទះមើលតំរងនោម ខ្ញុំធ្លាប់ជាប់ពន្ធនាគារ២ លើកហើយ លើកទី១ជាប់ខែកន្លះ។ ខ្ញុំអត់បានគិតទុកមុនទេទៅដល់ប៉ះឃើញលួចតែម្តង ពេលគេចាប់បានវាយខ្ញុំតែម្តង ហើយក៏បញ្ជូនឲ្យសមត្ថកិច្ច។ ពេលនេះខ្ញុំដឹងកំហុសហើយមានការស្តាយក្រោយទៀតផង ថ្ងៃក្រោយខ្ញុំឈប់ប្រព្រឹត្តទៀតហើយ។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានៈ** ក្រោយពីបានស្តាប់ការសួរដេញដោលនេះ តំណាងអយ្យការ យល់ឃើញថាៈ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **ភឿន** ពិតជាបាន **ប៉ុងប៉ងលួច (កាបូប)** ប្រាកដមែន ។ ផ្អែកតាមធាតុផ្សំនៃបទល្មើសកំណត់បានថា ជនជាប់ចោទឈ្មោះ[redacted] **ភឿន** ពិតជាបានប្រព្រឹត្តអំពើ **ប៉ុងប៉ងលួច(កាបូប)** ពិតប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសន្និដ្ឋានថាៈ ក្រោយពីការសាកសួរដេញដោល និងក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការរួចមកហើយឃើញថា កូនក្តីខ្ញុំពិតជាបានប៉ុនប៉ងលួចយកកាបូបរបស់ជនរងគ្រោះពិតមែន តែពេលនេះគាត់ដឹងកំហុសហើយ និងមានការស្តាយក្រោយយ៉ាងខ្លាំង ហេតុដូច្នេះសូមលោកស្រីចៅក្រមមេត្តាពិនិត្យ និងពិចារណាបន្ធូរបន្ថយទោសឲ្យគាត់ផង។

Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ភឿន បាននិយាយសំដីចុងក្រោយថាៈ ខ្ញុំបាទសំណូមពរ សុំឲ្យតុលាការ បន្ធូរបន្ថយទោសឲ្យខ្ញុំផង។

-ក្រោយពីបានដំណើរការកិច្ចសួរដេញដោល

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកំពត**

**យល់ឃើញថា**

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភឿន បានសារភាព និងបានទទួលស្គាល់ថាខ្លួន ពិតជាបានប្រព្រឹត្តបទល្មើស **ប៉ុងប៉ងលួច (កាបូប)** ពិតប្រាកដមែន គប្បីតុលាការពិចារណា ។

-ជនជាប់ចោទឈ្មោះ [redacted] ភឿន តាមសាវតាជាតិដែលទទួលបានអាចបញ្ជាក់ថា គឺជានីតិជន ដូច្នេះ តាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌបានចែងថាមាននីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និង ជាជនដែលមានការយល់ដឹងអាចថ្លឹងថ្លែងនូវអំពើរបស់ខ្លួនបាន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភឿន ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ ។

ពីបទៈ **ប៉ុងប៉ងលួច (កាបូប)** ប្រព្រឹត្តនៅចំណុចអាគារសង្គ្រោះបន្ទាន់ មន្ទីរពេទ្យបង្អែកខេត្តកំពត ស្ថិតនៅភូមិកំពង់បាយ សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត កាលពីវេលាម៉ោង ១ រំលងអធ្រាត្រ ឆ្លងចូលថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ [redacted] យេន មិនទាមទារសំណងទេ ដូច្នេះតុលាការ គប្បីមិនសម្រេចអំពីសំណងរដ្ឋប្បវេណីទេ ។

**ហេតុដូច្នេះសាលាដំបូងខេត្តកំពត**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទ

-ឈ្មោះ [redacted] ភឿន ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយខែ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ០៥ ខែ មករាឆ្នាំ២០២២។

ពីបទៈ **ប៉ុងប៉ងលួច (កាបូប)** ប្រព្រឹត្តនៅចំណុចអាគារសង្គ្រោះបន្ទាន់ មន្ទីរពេទ្យបង្អែកខេត្តកំពត ស្ថិតនៅភូមិកំពង់បាយ សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត កាលពីវេលាម៉ោង ១ រំលងអធ្រាត្រ ឆ្លងចូលថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

២-សាលក្រមប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] ភឿន ,ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យេន ។

ទុកសិទ្ធិអោយប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ចន្ទ ៦កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

[redacted]

Scanned with CamScanner